សូមគោរពឯកឧត្តមលោកជំទាវ អស់លោកលោកស្រីទាំងអស់

សូមគោរពលោកស្រី Tina Tan មកពី Civil Service College

សូមគោរពលោកស្រី Joanne Ng មកពី Temasek Foundation International,

ជាបឋម ខ្ញុំសូមសម្តែងក្តីរីករាយដែលបានចូលរួមក្នុងកម្មវិធីថ្ងៃនេះ គឺសិក្ខាសាលាស្តីពី "ការចែករំលែកបទពិសោធន៍ នៃការអនុវត្តគម្រោងអន្តរក្រសួងរបស់ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពមន្ត្រីជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា"។ ក្នុងនាមក្រសួងមុខងារសាធារណៈ និងមូលនិធិ Temasek អន្តរជាតិ ខ្ញុំសូមស្វាគមន៍ឯកឧត្តមលោកជំទាវ អស់លោកលោកស្រីទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងថ្ងៃនេះ។

សិក្ខាសាលានេះត្រូវបានរៀបចំធ្វើឡើង ក្រោមកិច្ចសហការរវាងក្រសួងមុខងារសាធារណៈ និងមូលនិធិ Temasek អន្តរជាតិ រួមជាមួយ Civil Service College សិង្ហបុរី ហើយជាផ្នែកមួយនៃបណ្តាកម្មវិធីបណ្តុះបណ្តាល ដើម្បីគាំទ្រដល់កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈរបស់កម្ពុជា។ ក្នុងពេលកន្លងមកយើងបានបញ្ចប់ដោយជោគជ័យ នូវកម្មវិធីចំនួនបួន។ កម្មវិធីបីដំបូងគឺសន្និសិទ (Symposium) ស្តីពីភាពជាអ្នកដឹកនាំដែលមានរយៈពេលពីរថ្ងៃ និងសិក្ខាសាលារយៈពេលបួនថ្ងៃចំនួន២ គឺសិក្ខាសាលាស្តីពី "ការកសាងសមត្ថភាពក្នុងការឆ្លើយតប យ៉ាងឆាប់រហ័សចំពោះការផ្លាស់ប្តូរ" និង "ការគ្រប់គ្រងនិងការអនុវត្តការផ្តល់សេវាដ៏ល្អប្រសើរ" ដែលកម្មវិធីទាំងបីនេះរៀបចំឡើងនៅសាលាភូមិន្ទរដ្ឋបាល នៅទីក្រុងភ្នំពេញព្រះរាជាណាចក្រកម្ពុជា។ កម្មវិធីទីបួនគឺជាដំណើរទស្សនកិច្ចសិក្សា លើបទពិសោធន៍ក្នុងការផ្តល់សេវាសាធារណៈរបស់សិង្ហបុរី (កម្មវិធីទស្សនកិច្ចសិក្សារបស់មន្ត្រីជាន់ខ្ពស់កម្ពុជា ទៅប្រទេសសិង្ហបុរី) ដែលកម្មវិធីនេះរៀបចំធ្វើឡើងនៅប្រទេសសិង្ហបុរី។ តាមរយៈនេះខ្ញុំសូមសម្តែងការកោតសរសើរដ៏ស្មោះចំពោះមូលនិធិ Temasek អន្តរជាតិ និង Civil Service College សិង្ហបុរី សម្រាប់ការជួយគាំទ្រ។

ឆ្លៀតឱកាសនេះខ្ញុំសូមជម្រាបថា រដ្ឋាភិបាលដែលជ្រើសរើសយក គំនិតផ្តួចផ្តើមលើកំណែទម្រង់ផ្នែកសាធារណៈ ចាំបាច់ត្រូវតែទទួលស្គាល់ពីសារសំខាន់និងភាពចាំបាច់ សម្រាប់គោលការណ៍អភិបាលកិច្ច និងការផ្តល់សេវាសាធារណៈនៅក្នុងសង្គម។ ដោយសារហេតុនេះហើយទើបនៅក្នុង កម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈរបស់កម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យ៉ាងច្បាស់ នូវចក្ខុវិស័យសម្រាប់កំណែទម្រង់រដ្ឋបាលថាជា "ការកែប្រែរដ្ឋបាលសាធារណៈ ទៅជាអ្នកផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធិភាព និងជាដៃគូគួរឲ្យទុកចិត្តដើម្បីបម្រើប្រជាជន ឲ្យកាន់តែល្អប្រសើរ"។ ក្នុងន័យនេះទើបកម្មវិធីបណ្តុះបណ្តាលទាំងនេះ ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតប ចំពោះតម្រូវការក្នុងការពង្រឹង

សមត្ថភាពដឹកនាំជាយុទ្ធសាស្ត្រ ក្នុងការអនុវត្តកំណែទម្រង់ទាំងបី របស់រាជរដ្ឋាភិបាលកម្ពុជាគឺៈ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈិការ។ បណ្តាកម្មវិធីបណ្តុះបណ្តាលទាំងនេះ មានគោលដៅដើម្បីបង្កើនសមត្ថភាព មន្ត្រីរាជការជាន់ខ្ពស់នៅតាមក្រសួង និងតាមបណ្តាខេត្តនានា ហើយនិងជួយដល់ការជម្រុញឲ្យមាន ការផ្លាស់ប្តូរជាប្រព័ន្ធ/ការផ្លាស់ប្តូរស្ថាប័ន នៅក្នុងផ្នែករដ្ឋបាលសាធារណៈកម្ពុជា។ សិក្ខាកាមចូលរួមក្នុងបណ្តាកម្មវិធីបណ្តុះបណ្តាលទាំងនេះ នឹងអាចប្រើប្រាស់បណ្តាចំណុចនានា ដែលទទួលបានពីការសិក្សាក្នុងកម្មវិធី អាចបង្កើតជាបណ្តាញនិងអាចធ្វើការចែករំលែកចំណេះដឹង ដើម្បីធ្វើឲ្យប្រសើរឡើងនូវការងាររបស់ពួកគាត់ ក្នុងការអនុវត្តគោលនយោបាយរដ្ឋាភិបាល ជាពិសេសកម្មវិធីកំណែទម្រង់ទាំងបី ដែលបានលើកឡើងពីខាងលើ។

នៅក្នុងកម្មវិធីទីបួន យើងមានដៃគូសហការដ៏ល្អគឺ យ Civil Service College សិង្ហបុរី។ ជាស្ថាប័នដែលមានបេសកកម្ម "អភិវឌ្ឍន៍បុគ្គលិកសម្រាប់ មុខងារសាធារណៈកម្រិតលេខ១" កម្មវិធីនិងសេវាបណ្តុះបណ្តាលរបស់ Civil Service College សិង្ហបុរី គឺផ្តោតលើការអនុវត្តជាក់ស្តែង។ ដោយមានទំនាក់ទំនងជាមួយថ្នាកដឹកនាំនៅវិស័យសាធារណៈ និងអ្នកគ្រប់គ្រងផ្នែកនោះ ទើបធ្វើឲ្យការបណ្តុះបណ្តាលត្រូវបានសម្របសម្រួលដោយអ្នកប្រតិបត្តិ ដែលមានបទពិសោធន៍ខ្ពស់ ដែលអាចផ្តល់នូវបទពិសោធន៍ផ្ទាល់ និងបទពិសោធន៍ក្នុងការបណ្តុះបណ្តាលមន្ត្រីមកពីប្រទេសដទៃផ្សេងទៀត។ អ្នកចូលរួមក្នុងកម្មវិធីនេះពិតជាបានទទួលបទពិសោធន៍ និងចំណេះដឹងតាមរយៈការពិភាក្សា ការប្រឹក្សា និងការចុះសិក្សាផ្ទាល់ដោយជួបជាមួយ អ្នករៀបចំគោលនយោបាយគន្លឹះ និងនៅតាមស្ថាប័នសាធារណៈក្នុងប្រទេសសិង្ហបុរី។

ដោយមានការប្តេជ្ញាចិត្តខ្ពស់ពីក្រុមការងារគម្រោង និងដោយមានការគាំទ្រជាបន្តបន្ទាប់ពីក្រសួងស្ថាប័នសាមី រួមជាមួយបទពិសោធន៍និងចំណេះដឹង ដែលទទួលបានពីទស្សនកិច្ចសិក្សានៅប្រទេសសិង្ហបុរី ទើបក្រុមនីមួយៗបានដំណើរការគម្រោងទៅដោយវិជ្ជមាននិងជាផ្លែផ្កា។ ដូច្នេះហើយទើបមានសិក្ខាសាលាក្នុងថ្ងៃនេះ ដែលមានគោលដៅក្នុងការចែករំលែកបទពិសោធន៍ លើការអនុវត្តគម្រោងអន្តរក្រសួងរបស់កម្មវិធីអភិវឌ្ឍន៍សមត្ថភាពមន្ត្រីជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា។ ព្រឹត្តិការណ៍ថ្ងៃនេះនឹងផ្តល់ជាឱកាសសម្រាប់សិក្សារៀនសូត្រពីអ្នកប្រតិបត្តិផ្ទាល់ ដែលបានចូលរួមក្នុងគម្រោងអន្តរក្រសួងជាក់ស្តែង ហើយដែលឯកឧត្តមលោកជំទាវ លោកលោកស្រីនៅក្នុងក្រុមការងារគម្រោង នឹងមកចែករំលែកនូវបទពិសោធន៍របស់ពួកគាត់ រួមជាមួយទស្សនទានថ្មីនិងការយល់ឃើញថ្មី អំពីការប្រឈម ចំណេះដឹងនិងបទពិសោធន៍ផ្ទាល់។ ខ្ញុំសង្ឃឹមថាឯកឧត្តមលោកជំទាវ លោកលោកស្រីទាំងអស់ នឹងប្រើប្រាស់អស់លទ្ធភាព

នូវឱកាសដ៏ពិសេសនៅក្នុងថ្ងៃនេះ ដើម្បីពង្រីកបន្ថែមនូវទស្សនៈនិងការយល់ឃើញថ្មី ពីកម្មវិធីសិក្ខាសាលានេះ។

ជាចុងក្រោយនិងជាថ្មីម្តងទៀត ខ្ញុំសូមកោតសរសើរដល់អ្នកសម្របសម្រួលកម្មវិធីក្នុងថ្ងៃនេះ និងថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការរវាង ក្រសួងមុខងារសាធារណៈនិងមូលនិធិ Temasek អន្តរជាតិ។

សូមអរគុណហើយខ្ញុំសូមប្រកាសបើកកម្មវិធីចាប់ពីពេលនេះ។